ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jan-2015, 15:36
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក |
| ភាគីដាក់ឯកសារ៖ | មេធាវីការពារក្តី ០០៣ |
| ដាក់ជូន៖ | អង្គជំនុំជម្រះតុលាការកំពូល |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៥ |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬអង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់មេធាវីការពារក្តី ០០៣ សុំធ្វើអន្តរាគមន៍ក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ នៅក្នុងករណី ០០២/០១ ក្នុងគោលបំណងលើកឡើងអំពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅ អ.វ.ត.ក.**

**ឬ ម្យ៉ាងទៀត ស្នើសុំការអនុញ្ញាតដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី* ស្តីពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Agniezska KLONOWIECKAMILART

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele Mwachande MUMBA

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ក្រុមមេធាវីការពារក្តីទាំងអស់**
**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈនេះ មេធាវីការពារក្ដី ០០៣ ស្នើសុំធ្វើអន្តរាគមន៍ដោយផ្ទាល់មាត់ និង ជាលាយលក្ខណ៍អក្សរ នៅក្នុងរឿងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី ០០២/០១ ដែលក្នុងនោះសហព្រះរាជអាជ្ញាប្ដឹងសាទុក្ខសាលក្រមករណី ០០២/០១ ដោយផ្អែកលើមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាលើទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម (“JCE III”)[1]។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះសេចក្ដីសម្រេចមួយលើភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅ អ.វ.ត.ក. នឹងប៉ះពាល់ដោយចៀសមិនរួចដល់មេធាវីការពារក្ដី ០០៣ ព្រមទាំងភាគីទាំងឡាយនៃរឿងក្ដី ០០២។ ម្យ៉ាងវិញទៀត អនុលោមតាមវិធាន៣៣ នៃវិធានផ្ទៃក្នុង អ.វ.ត.ក. (“វិធាន”) មេធាវីការពារក្ដី ០០៣ ស្នើសុំការអនុញ្ញាតដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* ដែលភ្ជាប់មកជាមួយ ស្ដីពីបញ្ហាថាតើ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III អាចត្រូវបានអនុវត្តនៅ អ.វ.ត.ក. ឬយ៉ាងណា។ សារណានេះបង្ហាញថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី III មិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ ១៩៧៥-១៩៧៩ នោះទេ ហើយហេតុដូច្នេះ មិនគួរយកទៅអនុវត្តនៅ អ.វ.ត.ក. ឡើយ។ សារណានេះមានបំណងជួយដល់អង្គជំនុំជម្រះតុលាការកំពូល[2]។ ចំណុចនេះគឺជាបញ្ហាកង្វល់ទូទៅរបស់អ្នកច្បាប់ផ្នែកច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលមានចំណាប់អារម្មណ៍នៅក្នុងការកំណត់ និង ការអនុវត្តឲ្យបានត្រឹមត្រូវនូវច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ សេចក្ដីសម្រេចមួយរបស់អង្គជំនុំជម្រះ

---

[1] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អ.ជ.ត.ក បណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្ដី ០០២/០១ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ F11។

[2] អង្គបុរេជំនុំជម្រះបានទទួលស្គាល់ភាពស្មុគស្មាញនៃបញ្ហានេះ និង បានអញ្ជើញឲ្យដាក់សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* ក្នុងរឿងក្ដី ០០១។ នៅក្នុងរឿងក្ដី ០០២ អង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីពន្យារពេលដាក់ឯកសារ និង បន្ថែមចំនួនទំព័រក្នុងការលើកឡើងអំពីបញ្ហានេះ។ *សូមមើល ឧទា. រឿងក្ដី កាំង ហ្កេកអ៊ាវ សំណុំរឿងលេខ* ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២) លិខិតអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្ដី *ចុះថ្ងៃទី* ២៣ ខែកញ្ញា ឆ្នាំ ២០០៨ ឯកសារ D99/3/12។ *រឿងក្ដី កាំង ហ្កេកអ៊ាវ សំណុំរឿងលេខ* ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២) លិខិតអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្ដី ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ D99/3/13 និង ឯកសារ D99/3/14។ *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត សំណុំរឿងលេខ* ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ ៣៥, ៣៧, ៣៨, ៣៩) សេចក្ដីសម្រេចលើសំណើសុំពន្យារពេល និង បន្ថែមចំនួនទំព័ររបស់សហព្រះរាជអាជ្ញាក្នុងការដាក់ចម្លើយរួមតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ខៀវ សំផន អៀង សារី និង ភាគីដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនប្រឆាំងនឹងដីកាសម្រេចលើសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០១០ ឯកសារ D97/16/4។

តុលាការកំពូល នឹងមានការជំពាក់ទាក់ទងនឹងតុលាការផ្សេងៗទៀត និង នឹងចូលរួមចំណែកដល់ការវិវត្តន៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ មេធាវីការពារក្តី ០០៣ មានបទពិសោធន៍ច្រើនទាក់ទិននឹងបញ្ហាឋានៈរបស់សហឧក្រិដ្ឋកម្មរួមនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារតែសហមេធាវី Michael G. Karnavas បានស្រាវជ្រាវ និង ដោះស្រាយបញ្ហានេះនៅក្នុងរឿងក្តីជាច្រើនចាប់តាំងពីឆ្នាំ ២០០១ មក តែក្នុងរយៈពេលពីរឆ្នាំប៉ុណ្ណោះក្រោយពីការបង្កើតសហឧក្រិដ្ឋកម្មរួមទម្រង់ទី III របស់អង្គជំនុំជម្រះតុលាការកំពូល *Tadić*[3]។

## I. ឧទ្ធិករណ៍គាំទ្រការអន្តរាគមន៍របស់មេធាវីការពារក្តី ០០៣ ក្នុងនាមជាភាគីមានផលប្រយោជន៍នៅក្នុងរឿងក្តី ០០២

១. ប្រសិនបើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចជំនុំជម្រះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III បើទោះបីជា បណ្តឹងសាទុក្ខនេះត្រូវបានមើលឃើញថា មិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែតក៏ដោយ[4] អង្គជំនុំជម្រះតុលាការ

---

[3] *សូមមើល ឧ.ទា.* Michael G. Karnavas *សហឧក្រិដ្ឋកម្មរួមនៅឯ អ.វ.ត.ក.៖ ការវិភាគស៊ីជម្រៅលើបទអត្ថាធិប្បាយដែលខ្វែងគ្នាចំនួនពីរទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះប្រឆាំងនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួម* 21 CRIM. L.F. 445 (២០១០)។ *សូមមើលផងដែរ* គេហទំព័ររបស់មេធាវីការពារក្តី អៀង សារី ដែលមាននៅឯ www.iengsarydefence.org ដែលរៀបរាប់បញ្ជីឯកសារទាំងអស់ដែលទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម ដែលបានដាក់ដោយមេធាវីការពារក្តី អៀង សារី។

[4] វិធាន ១០៤(១) បើកឱ្យប្តឹងសាទុក្ខលើកំហុសអង្គច្បាប់ដែលនាំឱ្យសាលក្រមមោឃៈ ហើយសហព្រះរាជអាជ្ញាបានទទួលស្គាល់ថា ពួកគេពុំបានស្នើសុំឱ្យច្រានចោលផ្នែកណាមួយនៃសាលក្រមឡើយ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាផ្អែកលើ "វិធាននីតិវិធីដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិ" ដើម្បីតវ៉ាថា សំណើសុំបកស្រាយច្បាប់អាចធ្វើឡើងបាន។ ទោះជាយ៉ាងនេះក៏ដោយ មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អនុញ្ញាតឱ្យប្រើប្រាស់វិធាននីតិវិធីក្នុងកម្រិតអន្តរជាតិតែ "ក្នុងករណីដែលច្បាប់កម្ពុជាពុំមានចែងអំពីបញ្ហាជាក់លាក់ណាមួយ ឬ ក្នុងករណីដែលមានភាពមិនប្រាកដប្រជាទាក់ទងនឹងការបកស្រាយ ឬ ការអនុវត្តវិធានពាក់ព័ន្ធនៅក្នុងច្បាប់កម្ពុជា ឬ ក្នុងករណីដែលមានបញ្ហាចោទណាមួយពាក់ព័ន្ធនឹងភាពស្របគ្នានៃវិធានបែបនេះជាមួយនឹងបទដ្ឋានអន្តរជាតិ"។ សហព្រះរាជអាជ្ញាពុំបានបង្ហាញថា កាលៈទេសៈទាំងនេះបានកើតឡើងនោះទេ ហើយក៏ពុំបានបង្ហាញផងដែរថា វិធាននីតិវិធីនៅកម្រិតអន្តរជាតិនឹងអនុញ្ញាតឱ្យប្តឹងសាទុក្ខបែបនេះ។ វិធាននៅសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ពុំបានចែងច្បាស់លាស់អំពីសិទ្ធិប្តឹងសាទុក្ខនៅពេលស្នើសុំឱ្យបកស្រាយច្បាប់នោះឡើយ។ លើសពីនេះទៅទៀត សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខបានដាក់ខុសទៅអង្គជំនុំជម្រះមួយផ្សេង។ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ខណៈដែលវិធាន ១០៦(២) តម្រូវឱ្យដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះសាលាដំបូង (និង បន្ទាប់មក វិធាន ១០៦(៥) តម្រូវឱ្យដាក់សារណាបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះ

កំពូលត្រូវតែអនុញ្ញាតឲ្យមេធាវីការពារក្ដី ០០៣ ធ្វើអន្តរាគមន៍ដោយចូលរួមតាមរយៈទឡ្ហីករណ៍ផ្ទាល់មាត់ និងដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។ គ្មានច្បាប់ ឬ វិធាននីតិវិធីណាមួយចែងហាមឃាត់ការអន្តរាគមន៍បែបនេះឡើយ ហើយនេះគឺជាបញ្ហាមួយដែលនឹងប៉ះពាល់ធ្ងន់ធ្ងរដល់រឿងក្ដី ០០៣៖ ជនសង្ស័យនៅក្នុងរឿងក្ដី ០០៣ ត្រូវបានសហព្រះរាជអាជ្ញាចោទប្រកាន់ថាជាសមាជិកមួយរូបនៅក្នុងសហឧក្រិដ្ឋកម្មរួម និងបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ ដែលដាក់គាត់ឲ្យទទួលខុសត្រូវ ដោយប្រើសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នេះ[5]។

២. ការបដិសេធមិនអនុញ្ញាតឲ្យមេធាវីការពារក្ដីធ្វើអន្តរាគមន៍ ដោយផ្អែកលើមូលដ្ឋានថា ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III អាចត្រូវបានជំទាស់តវ៉ានៅក្នុងរឿងក្ដី ០០៣ ក្នុងដំណាក់កាលក្រោយទៀតនោះ ពុំបានការពារគ្រប់គ្រាន់នូវផលប្រយោជន៍របស់មេធាវីការពារក្ដី ០០៣ នោះទេ ហើយវានឹងពុំមែនជាការសន្សំសំចៃរបស់តុលាការដែរ។ អង្គជំនុំជម្រះតុលាការកំពូលទំនងជាពុំចេញសេចក្ដីសម្រេចលើបញ្ហាច្បាប់សុទ្ធសាធនេះនៅក្នុងរឿងក្ដី ០០៣ ខុសពីសេចក្ដីសម្រេចដែលខ្លួននឹងចេញនៅក្នុងរឿងក្ដី ០០២ នោះឡើយ (ហើយករណីនេះក៏ពុំសមស្របផងដែរ ដោយសារថា វានឹងរំលោភលើសិទ្ធិទទួលបានការប្រព្រឹត្តិស្មើភាពគ្នាផងដែរ)។

៣. សំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅក្នុងករណី ០០២ ដែលមិនអនុញ្ញាតឲ្យមេធាវីការពារក្ដី អៀង សារី ធ្វើអន្តរាគមន៍នៅក្នុងរឿងក្ដី ០០១ ដើម្បីលើកឡើងអំពីបញ្ហាភាពអាចអនុវត្តបាននៃ

---

តុលាការកំពូល)។ នីតិវិធីនេះអនុវត្តដូចគ្នាចំពោះបណ្ដឹងឧទ្ធរណ៍នៅមុនអង្គសេចក្ដី ពោលគឺ សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ត្រូវដាក់នៅចំពោះមុខ ក.ស.ច.ស. ហើយ បន្ទាប់មក បណ្ដឹងឧទ្ធរណ៍ត្រូវដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ *សូមមើល* វិធាន ៧៥(២)-(៣) នៃវិធានផ្ទៃក្នុង។ សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍គួរតែត្រូវបានច្រានចោលក្នុងករណីខកខានមិនបានបំពេញតាមលក្ខខណ្ឌនៃការដាក់បណ្ដឹង។

[5] ព័ត៌មាននេះអាចរកបាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៃរឿងក្ដី ០០៣ ដែលផ្សាយជាសាធារណៈ។ *សូមមើល* http://img.scoop.co.nz/media/pdfs/1106/CambodiaSecond_Introductory_Submission.redacted.pdf។ កថាខណ្ឌ ៩៧ លើកឡើងថា (គូសបញ្ជាក់បន្ថែម និង កោសលុបឈ្មោះជនសង្ស័យ)៖ “នៅពេលដែល [redacted] និង [redacted] បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ជនទាំងនេះបានធ្វើជាលក្ខណៈបុគ្គល ឬ តាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមជាមួយនឹងសហចារីផ្សេងទៀត ដែលបានកំណត់នៅក្នុងកថាខណ្ឌ ៣៣ ដល់ ៤១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ។ បទឧក្រិដ្ឋទាំងនេះគឺជាកម្មវត្ថុនៃសហឧក្រិដ្ឋកម្មរួម *ឬ ម្យ៉ាងទៀត ជាផលវិបាកធម្មតា និង ដែលអាចទស្សន៍ទាយបាននៃសហឧក្រិដ្ឋកម្មរួម* ។ សមាជិកផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួមបានប្រព្រឹត្តទៅតាមមូលដ្ឋាននៃគោលបំណងរួម ហើយដោយមានចេតនាដូចគ្នា”។

សហឧក្រិដ្ឋកម្មរួម ពុំអាចយកមកអនុវត្តនៅក្នុងស្ថានភាពនេះទេ។ នៅក្នុងសេចក្តីសម្រេចនោះ អង្គបុរេជំនុំជម្រះបានថ្លែងថា៖ "[ប]ណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា *គឺពាក់ព័ន្ធនឹងបទចោទដែល ឌុច ត្រូវបានបញ្ជូនទៅជំនុំជម្រះ*។ ដូច្នេះ សេចក្តីសម្រេចដែលនឹងចេញដោយអង្គបុរេជំនុំជម្រះនឹងមិនអនុវត្តផ្ទាល់ចំពោះ អៀង សារី ឡើយ ដែលគាត់នៅមានលទ្ធភាពតវ៉ាការអនុវត្តន៍ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ដែលគាត់ជាភាគីមួយនៃរឿងក្តី"[6]។ នៅក្នុងករណីនេះ សហព្រះរាជអាជ្ញា *ពុំបាន* ស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលច្រានចោលផ្នែកណាមួយនៃសាលក្រមរឿងក្តី ០០២/០១ ឡើយ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាស្នើសុំឲ្យបកស្រាយច្បាប់។ សហព្រះរាជអាជ្ញាប្រាថ្នាចង់ឲ្យអង្គជំនុំជម្រះតុលាការកំពូលប្រកាសថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី III អាចយកមកអនុវត្តបានដើម្បី "ផ្តល់ជាការណែនាំផ្លូវច្បាប់ដល់អង្គជំនុំជម្រះសាលាដំបូង"[7] ពោលគឺ ករណីនេះចាំបាច់ធ្វើឡើងតែក្នុងករណីដែលសហព្រះរាជអាជ្ញាមានបំណងយកសហឧក្រិដ្ឋកម្មរួមទម្រង់ទី III មកអនុវត្តនៅក្នុងការជំនុំជម្រះទាំងឡាយនាពេលខាងមុខតែប៉ុណ្ណោះ។

៤. សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា មូលហេតុពិតប្រាកដដែលពួកគេបានដាក់បណ្តឹងសារទុក្ខរបស់ពួកគេនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល គឺពីព្រោះពួកគេចង់ឲ្យមានអានុភាពលើការអនុវត្តច្បាប់នៅក្នុងការជំនុំជម្រះក្តីនាពេលអនាគត។ នៅក្នុងសារអេឡិចត្រូនិចផ្ញើទៅកាន់អ្នកសារព័ត៌មាន សហព្រះរាជអាជ្ញារងអន្តរជាតិ William Smith បាននិយាយថា អង្គជំនុំជម្រះសាលាដំបូងគួរតែបានពិចារណាទៅលើបទឧក្រិដ្ឋកម្មដែលអាចព្យាករណ៍ឃើញជាមុន ដោយបានអះអាងថា៖ "ទោះបីជា ជនជាប់ចោទទាំងពីរត្រូវបានផ្តន្ទាទោសហើយក៏ដោយ ក៏ជាការសំខាន់ក្នុងការមានការទទួលស្គាល់នូវទម្រង់នៃការទទួលខុសត្រូវបែបនេះ ដោយហេតុថា វាអាចជះ

---

[6] *រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០២) សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាដំណោះស្រាយលើករណី កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០០៨ ឯកសារ D99/3/19 កថាខណ្ឌ ១២ (គូសបញ្ជាក់បន្ថែម)។

[7] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចមួយនៅក្នុងរឿងក្តី ០០២/០១ ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០០៨ ឯកសារ E313/3/1 កថាខណ្ឌ ៩។

ឥទ្ធិពលលើការជំនុំជម្រះក្តីនាពេលអនាគត ទាក់ទងនឹងបទឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ដូចជា រំលោភសេពសន្ធវៈជាដើម ដែលអាចនឹងមិនមានការញុះញង់ ការបង្គាប់បញ្ជា ឬ ការរៀបចំផែនការជាមុន ប៉ុន្តែ អាចត្រូវបានមើលឃើញជាមុនដោយសារសកម្មភាពរបស់ជនជាប់ចោទ”[8]។

៥. ប្រសិនបើពុំច្រានចោលបណ្តឹងសាទុក្ខ ដែលពុំអាចទទួលយកបានយ៉ាងច្បាស់ក្រឡែតនេះតែម្តងទេ នោះ ជាការសន្សំសំចៃរបស់តុលាការ ក្នុងការស្តាប់ទឡ្ហីករណ៍របស់មេធាវីការពារក្តី ០០៣ (និង មេធាវីការពារក្តី ០០៤ ប្រសិនបើស្នើសុំ) និង ដោះស្រាយបញ្ហាភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី III ឲ្យដាច់ស្រឡះក្នុងពេលនេះតែម្តងជាលើកចុងក្រោយ។

៦. នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (“តុលាការ SCSL”) អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឲ្យ Augustine Gbao និង Moinina Fofana (ជនជាប់ចោទនៅក្នុងរឿងក្តីផ្សេងទៀតនៅតុលាការ SCSL) ធ្វើអន្តរាគមន៍នៅក្នុងរឿងក្តី *Kallon និង Kamara* ទាក់ទងនឹងភាពអាចអនុវត្តបាននៃការអនុគ្រោះទោសដល់ Lomé Accord ដោយបានទទួលស្គាល់ថា សេចក្តីសម្រេចមួយស្តីពីសុពលភាពនៃការអនុគ្រោះទោស នឹងប៉ះពាល់ដល់ជនជាប់ចោទទាំងនេះផងដែរ[9]។ អង្គបុរេជំនុំជម្រះក៏បានអញ្ជើញភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី ០០១ ឲ្យដាក់សេចក្តីសន្និដ្ឋានលើពាក្យសុំដែលបានធ្វើឡើងនៅក្នុងរឿងក្តី ០០២ ផងដែរ ដោយផ្អែកលើមូលដ្ឋានថា ការសម្រេចសេចក្តីលើពាក្យសុំនេះនឹងឈានទៅរកការចេញសេចក្តីណែនាំទូទៅ ស្តីពីសិទ្ធិក្នុងការថ្លែងជូនតុលាការរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលពុំមានមេធាវីតំណាង ហើយដូច្នេះវានឹងប៉ះពាល់ដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី ០០១ និង ០០២[10]។

---

[8] Holly Robertson *អយ្យការប្តឹងឧទ្ធរណ៍ទៅសាលាក្តីខ្មែរក្រហមសុំពង្រីកវិសាលភាព* (Prosecution Appeals to KR Tribunal to Widen Scope) សារព័ត៌មាន ឌឹខេមបូឌាដេលី ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៤ ទំព័រ ៤។

[9] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kallon & Kamara សំណុំរឿងលេខ* SCSL-2004-15-AR72(e) សេចក្តីសម្រេចលើការជំទាស់តវ៉ាទៅនឹងយុត្តាធិការ៖ ការអនុគ្រោះទោសដល់ Lomé Accord ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៤ (*សូមមើល* ក្របទំព័រ ដាក់ឈ្មោះ Gbao និង Fofana ជាអ្នកអន្តរាគមន៍ និង ទំព័រ ៣ ដែលបានកត់សម្គាល់ថា Gbao និង Fofana បានដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតាមការអនុញ្ញាតរបស់តុលាការ)។

[10] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តីសហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹង

៧. កិច្ចអន្តរាគមន៍របស់ភាគីទីបីនៅក្នុងបណ្តឹងសាទុក្ខក្នុងរឿងក្តីព្រហ្មទណ្ឌ គឺជាបញ្ហាធម្មតានៅតាមបណ្តាតុលាការផ្សេងទៀតផងដែរ។ ឧទាហរណ៍ នៅក្នុងប្រទេសកាណាដា "ការអន្តរាគមន៍របស់ភាគីទី[បី]បានក្លាយជានិយាមមួយ ជាជាងករណីលើកលែងនៅក្នុងរឿងក្តីទាំងឡាយនៅចំពោះមុខតុលាការកំពូល កាណាដា" កិច្ចអន្តរាគមន៍របស់ភាគីទីបីត្រូវបានស្វាគមន៍ និង លើកទឹកចិត្ត ដើម្បីឲ្យតុលាការមានព័ត៌មាន ទស្សនៈ និង ទស្សនទានទូលំទូលាយបំផុតនៅពេលសម្រេចសេចក្តី[11]។ ការធ្វើបែបនេះក៏កំពុងតែក្លាយជាទម្លាប់ធម្មតានៅចំពោះមុខសភាជាន់ខ្ពស់ (House of Lords) ក្នុងចក្រភពអង់គ្លេសដែរ[12]។

៨. កិច្ចអន្តរាគមន៍នេះនឹងពុំបណ្តាលឲ្យមានព្យសនកម្មដល់ភាគីណាមួយនោះទេ ដោយហេតុថាសហព្រះរាជអាជ្ញាបានស្នើសុំតែឲ្យ *បកស្រាយច្បាប់* ប៉ុណ្ណោះ បានន័យថា គ្មានទស្សនៈណាមួយដែលលើកឡើងដោយមេធាវីការពារក្តី ០០៣ អាចនឹងប៉ះពាល់ដល់សាលក្រមក្នុងរឿងក្តី ០០២/០១ នោះទេ ទោះក្នុងករណីណាក៏ដោយ។ កិច្ចអន្តរាគមន៍នេះនឹងជាប្រយោជន៍ដ៏ប្រពៃបំផុតសម្រាប់ភាគីទាំងអស់ និង អង្គជំនុំជម្រះតុលាការកំពូល ដែលទទួលបានប្រយោជន៍ពីទស្សនៈជាលាយលក្ខណ៍អក្សរ និង ផ្ទាល់មាត់របស់មេធាវីការពារក្តី ០០៣ លើបញ្ហាស្មុគស្មាញនេះ។

---

ឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាដំណោះស្រាយ លើករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ១១ ដែលសំដៅលើសេចក្តីណែនាំដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ដែលទំនងជាព័ត៌មានសម្ងាត់។

[11] Andrea C. Loux *ស្តាប់ "សម្លេងមួយផ្សេងពីនេះ"៖ ការអន្តរាគមន៍របស់ភាគីទីបីនៅក្នុងបណ្តឹងសាទុក្ខក្នុងរឿងក្តីព្រហ្មទណ្ឌ* ៥៣(១) បញ្ហាគតិយុត្តិក្នុងពេលបច្ចុប្បន្ន ៤៤៩ ៤៥២-៥៣ (ឆ្នាំ ២០០០)។

[12] *ដូចខាងលើ* ត្រង់ ៤៥៤។

## II. ឧត្តមគ្រែកុណ៍គាំទ្រដល់មេធាវីការពារក្ដី ០០៣ ក្នុងការបំពេញតួនាទីជា *អ្នកដែលមិនមែនជាភាគី* នៃរឿងក្ដី ០០២

៩. ប្រសិនបើ អង្គជំនុំជម្រះតុលាការកំពូលសម្រេចមិនអនុញ្ញាតឱ្យមេធាវីការពារក្ដី ០០៣ ធ្វើការអន្តរាគមន៍ដោយផ្ទាល់នៅក្នុងកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខក្នុងរឿងក្ដី ០០២/០១ ក្នុងគោលបំណងលើកឡើងពីភាពអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ នោះទេ មេធាវីការពារក្ដី ០០៣ សូមស្នើសុំបំពេញតួនាទីជា *អ្នកដែលមិនមែនជាភាគី* ។ វិធាន ៣៣ មិនបានដាក់ព្រំដែនលើអ្នកដែលអាចបំពេញតួនាទីជា *អ្នកដែលមិនមែនជាភាគី* ឡើយ បុគ្គល ឬ អង្គការណា ក៏អាចទទួលបានការអនុញ្ញាតឱ្យដាក់សារណារបស់ *អ្នកដែលមិនមែនជាភាគី* ដែរ ប្រសិនបើអង្គជំនុំជម្រះពិចារណាឃើញថា គួរទទួលយកសារណានេះ ដើម្បីការកាត់សេចក្ដីដ៏ត្រឹមត្រូវនៃរឿងក្ដី។ មិនមានភាគីណាមួយនឹងទទួលរងព្យសនកម្ម ដោយការដាក់សារណារបស់ *អ្នកដែលមិនមែនជាភាគី* នេះឡើយ ព្រោះវិធាន ៣៣(២) ចែងថា ភាគីមានសិទ្ធិធ្វើការឆ្លើយតបទៅនឹងសារណានេះ។ គ្មានការពន្យារពេលកិច្ចដំណើរការនីតិវិធីនឹងកើតឡើងឡើយ។

១០. នៅក្នុងរឿងក្ដី ០០១ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលពាក្យសុំរបស់អង្គភាពគាំពារការការពារក្ដី ("អ.គ.ក.") ដែលស្នើសុំការអនុញ្ញាតដាក់សារណារបស់ *អ្នកដែលមិនមែនជាភាគី* លើបញ្ហាទាក់ទងបណ្ដឹងសាទុក្ខរបស់ ឌុច ប្រឆាំងនឹងសាលក្រមរឿងក្ដី ០០១[13]។ ជាជាងបំពេញអាណត្តិការងាររបស់ខ្លួនក្នុងការផ្ដល់ជំនួយផ្នែកច្បាប់ និង ការគាំទ្រដល់ក្រុមមេធាវីការពារក្ដី ដូចមានចែងនៅក្នុងវិធាន ១១(២)(ញ) អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វាជាចេតនារបស់ អ.គ.ក. ក្នុងការបំពេញបន្ថែមលើសារណាបណ្ដឹងសាទុក្ខរបស់ ឌុច ហើយដោយសារការធ្វើបែបនេះ អង្គភាពនេះបានដើរតួនាទីជាមេធាវីការពារក្ដីជំនួស តាមរយៈសារណារបស់ *អ្នកដែលមិនមែនជាភាគី* នេះ[14]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "ក្នុងកាលៈទេសៈនេះ" *អ្នកដែលមិន*

---

[13] *រឿងក្ដី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្ដីសម្រេចលើសំណើរបស់ អ.គ.ក. សុំដាក់សារណារបស់ អ្នកដែលមិនមែនជាភាគី មកកាន់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០១០ ឯកសារ F7/2។

[14] *ដូចខាងលើ* កថាខណ្ឌ ៨-៩។

*មែនជាភាគី* គួរតែមិនជាប់ពាក់ព័ន្ធនឹងតុលាការ ឬ ការិយាល័យណាមួយរបស់តុលាការឡើយ[15]។

១១. ក្នុងកាលៈទេសៈបច្ចុប្បន្ន គឺមិនដូចនៅនឹងរឿងក្តី ០០១ ឡើយ។ មេធាវីការពារក្តី ០០៣ មិនមានចេតនា ហើយក៏មិនមានផលប្រយោជន៍ក្នុងការដើរតួនាទីជាមេធាវីការពារក្តីជំនួសសម្រាប់ នួន ជា ឬ ខៀវ សំផន ឡើយ។ សារណារបស់ *អ្នកដែលមិនមែនជាភាគី* ដែលភ្ជាប់មកជាមួយនេះ មិនត្រូវបានដាក់ក្នុងគោលបំណងជួយដល់ការការពារក្តីរបស់ពួកគេទេ។ មេធាវីការពារក្តី ០០៣ មិនមានផលប្រយោជន៍ក្នុងរឿងក្តីជាក់លាក់ប្រឆាំងនឹង នួន ជា ឬ ខៀវ សំផន ឡើយ ប៉ុន្តែ គឺមានផលប្រយោជន៍នៅក្នុងបញ្ហា ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ជាទូទៅប៉ុណ្ណោះ ដោយសារតែសេចក្តីសម្រេចណាមួយនៅក្នុងរឿងក្តី ០០២ នឹងប៉ះពាល់ដល់រឿងក្តី ០០៣ ហើយអាចមានផលប៉ះពាល់យ៉ាងទូលំទូលាយផងដែរ។ មេធាវីការពារក្តី ០០៣ មិនមានគម្រោងដែលលាក់លៀមឡើយ[16] ហើយផលប្រយោជន៍របស់មេធាវីការពារក្តីមានភាពច្បាស់លាស់ និង តម្លាភាព។ អង្គជំនុំជម្រះតុលាការកំពូលពិតជានឹងគិតពិចារណាដល់ផលប្រយោជន៍របស់មេធាវីការពារក្តី ០០៣ ប្រសិនបើអង្គជំនុំជម្រះសម្រេចទទួលយកសារណា *អ្នកដែលមិនមែនជាភាគី* របស់មេធាវីការពារក្តី ០០៣ អំពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី III។

១២. ជាការពិត វាជារឿងធម្មតាដែល *អ្នកដែលមិនមែនជាភាគី* (*amici curiae*) មានផលប្រយោជន៍លើបញ្ហាផ្លូវច្បាប់ ដែលបានលើកឡើងនៅក្នុងរឿងក្តីមួយ ដោយមិនគិតថា ពួកគេពាក់ព័ន្ធ ឬ មិនពាក់ព័ន្ធជាមួយលទ្ធផលនៃរឿងក្តីជាក់លាក់ឡើយ។ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់

---

[15] *ដូចខាងលើ* កថាខណ្ឌ ៩។

[16] នៅក្នុងសេចក្តីសម្រេច ដែលអនុញ្ញាតឲ្យ អ្នកដែលមិនមែនជាភាគី ធ្វើអន្តរាគមន៍ជាលាយលក្ខណ៍អក្សរ និង តាមរយៈទូរទស្សន៍ផ្ទាល់មាត់ អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ SCSL បានថ្លែងថា៖ "យើងមិនចាត់ទុកថា ពួកគេស្វែងរកការអនុញ្ញាតឲ្យធ្វើការអន្តរាគមន៍ ដោយមានមូលហេតុសម្ងាត់ណាមួយទេ ឧទាហរណ៍ដូចជា ដើម្បីផ្តល់ជាវេទិកាផ្សព្វផ្សាយជាសាធារណៈអំពីខ្លួនគេ ឬក៏ ដើម្បីប្រើប្រាស់អភ័យឯកសិទ្ធិ និង បុព្វសិទ្ធិរបស់តុលាការ ដើម្បីដាក់សេចក្តីប្រកាសទៅក្នុងកំណត់ត្រា ឬក៏ ដើម្បីបង្កើតគម្រោងលាក់លៀមនោះឡើយ"។ *រដ្ឋអាជ្ញា* តទល់នឹង *Kallon* សំណុំរឿងលេខ SCSL-2003-07-PT សេចក្តីសម្រេចលើពាក្យសុំរបស់ Redress Trust គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្ស និង គណៈកម្មការអន្តរជាតិសម្រាប់អ្នកច្បាប់ សុំអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី និង សុំបង្ហាញសារណាដោយផ្ទាល់មាត់ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០០៣ កថាខណ្ឌ ៧។

ប្រទេសរវ៉ាន់ដា អង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី Bogosora បានពន្យល់ថា៖

ជាបញ្ហាបឋម យើងកត់សម្គាល់ឃើញថា និយមន័យទូទៅនៃអ្នកដែលមិនមែនជាភាគីនៃរឿងក្តី មិនទាមទារឲ្យមានភាពមិនលម្អៀងរបស់ភាគីដាក់សារណានោះឡើយ។ អង្គជំនុំជម្រះគ្រាន់តែធ្វើការពិចារណាថា សារណាបែបនេះត្រូវបានដាក់ដោយភាគីមួយ ដែលមិនមែនជាផ្នែកនៃបណ្តឹង តែជាអ្នកដែលមានផលប្រយោជន៍ខ្លាំង ឬ មានទស្សនៈលើរឿងក្តីនៅចំពោះមុខតុលាការ[17]។

១៣. នៅឯតុលាការ SCSL អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី Kallon យល់ឃើញថា៖

ក្នុងពេលថ្មីៗនេះ តុលាការជាន់ខ្ពស់នៅចក្រភពអង់គ្លេស និង អូស្ត្រាលី មានបំណងផ្តល់ការអនុញ្ញាតដល់ភាគីដែលពាក់ព័ន្ធ ដូចជា សាជីវកម្ម ឬ អង្គការមិនមែនរដ្ឋាភិបាល ឲ្យដាក់សារណាលើចំណុចនៃអង្គច្បាប់ ដែលលេចឡើងក្នុងរឿងក្តីនៅចំពោះមុខតុលាការទាំងនោះ ដែលនេះគឺជាការអនុវត្តដែលត្រូវបានអនុម័តយកតាំងពីយូរណាស់មកហើយដោយតុលាការកំពូលរបស់សហរដ្ឋអាមេរិក។ ភាគីដែលធ្វើអន្តរាគមន៍ អាចមានផលប្រយោជន៍ផ្ទាល់ ពីព្រោះសេចក្តីសម្រេចនេះប្រហែលជានឹងអាចបង្កើតជាយុត្តិសាស្ត្រ ដែលជះឥទ្ធិពលលើពួកគេនៅថ្ងៃអនាគត។ ផលប្រយោជន៍របស់អ្នកធ្វើអន្តរាគមន៍ អាចមានលក្ខណៈមិនផ្ទាល់ គឺក្នុងន័យដែលថា រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ ក្រុមដែលធ្វើយុទ្ធនាការ អាចមានបំណងចង់ឲ្យមានការស្រាយបំភ្លឺ ឬ ការប្រកាស ឬ ការបង្កើតច្បាប់ ទៅតាមវិធីជាក់លាក់ណាមួយ។ ឧទាហរណ៍មួយនៃការអនុញ្ញាតឲ្យធ្វើអន្តរាគមន៍នៅក្នុងបញ្ហាប្រហាក់ប្រហែលគ្នានឹងបញ្ហានេះ គឺការផ្តល់ការអនុញ្ញាតដោយសភាជាន់ខ្ពស់អង់គ្លេស (House of

---

[17] *រដ្ឋអាជ្ញា* តទល់នឹង *Bagosora* សំណុំរឿងលេខ ICTR-96-7-T សេចក្តីសម្រេចលើសំណើរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ដោយរដ្ឋាភិបាលប្រទេសប៊ែលហ្ស៊ិក ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ១៩៩៨។ នៅក្នុងឆ្នាំ ២០០៧ សេចក្តីសម្រេចនេះត្រូវបានទុកជាមោឃៈ បន្ទាប់ពីរដ្ឋាភិបាលប៊ែលហ្ស៊ិក មិនបានដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ហើយការទទួលយកភស្តុតាងត្រូវបានបញ្ចប់រួចរាល់។ អង្គជំនុំជម្រះបានសម្រេចថា ខ្លួនបានស្តាប់ភស្តុតាងយ៉ាងច្រើនអំពីបញ្ហាដែលរដ្ឋាភិបាលប៊ែលហ្ស៊ិក បានស្នើសុំលើកឡើងជាបឋម ហើយក៏សម្រេចថា សារណារបស់ *អ្នកដែលមិនមែនជាភាគី* មិនអាចជួយដល់អង្គជំនុំជម្រះក្នុងការសម្រេចដោយត្រឹមត្រូវទៅលើរឿងក្តីបានឡើយ។ សូមមើល *រដ្ឋអាជ្ញា* តទល់នឹង *Bagosora* សំណុំរឿងលេខ ICTR-98-41-T ការពិចារណាទៅលើសេចក្តីសម្រេចលើកមុនអំពីពាក្យសុំរបស់ *អ្នកដែលមិនមែនជាភាគី* ដោយប្រទេសប៊ែលហ្ស៊ិក ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០០៧។

Lords) នៅក្នុងរឿងក្ដី Pinochet ដែលអង្គការអនុគ្រោះទោសអន្តរជាតិ (Amnesty International) ត្រូវបានអនុញ្ញាតឲ្យដាក់សារណា ហើយលើកជាទឡ្ហីករណ៍ផ្ទាល់មាត់ ក្នុងខណៈពេលដែលអង្គការដទៃទៀត ដូចជា អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) (ជាអង្គការមិនមែនរដ្ឋាភិបាល ដែលជាសម្ព័ន្ធមិត្តជាមួយគណៈកម្មាធិការមេធាវី) ត្រូវបានអនុញ្ញាតឲ្យដាក់សារណាជាលាយលក្ខណ៍អក្សរ...។ បញ្ហាគឺនៅត្រង់ថាតើ ជាការប្រសើរដែរឬទេក្នុងការទទួលជំនួយបែបនេះ ហើយពាក្យថា "ប្រសើរ" មិនមែនមានន័យថា "សំខាន់" (ដែលមានលក្ខណៈរឹតបន្តឹងហួសហេតុ) ហើយក៏មិនមែនមានន័យធូររលុងហួសហេតុ ដូចជាពាក្យ "ងាយស្រួល" ឬ "គួរឲ្យចាប់អារម្មណ៍" នោះដែរ។ ឆន្ទានុសិទ្ធិនឹងត្រូវបានប្រើប្រាស់ដោយជ្រើសរើសយកសំណើសុំដែលមានសំអាងហេតុពិតប្រាកដ ធ្វើឲ្យជឿជាក់បានថា សារណាជាលាយលក្ខណ៍អក្សរ ឬ សារណាដែលបំពេញបន្ថែមដោយទឡ្ហីករណ៍ផ្ទាល់មាត់ នឹងជួយដល់តុលាការក្នុងការឈានទៅដល់ការធ្វើសេចក្ដីសម្រេចបានត្រឹមត្រូវចំពោះបញ្ហានៅចំពោះមុខខ្លួន[18]។

១៤. អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី Kallon បានពន្យល់បន្ថែមទៀតថា អង្គជំនុំជម្រះតុលាការកំពូលមួយអាចប្រកាន់ទស្សនៈបែបបើកទូលាយចំពោះការទទួលយកសារណារបស់ *អ្នកដែលមិនមែនជាភាគី* ច្រើនជាងអង្គជំនុំជម្រះសាលាដំបូង ដោយសារតែការណ៍ដែលថា អង្គជំនុំជម្រះសាលាដំបូងត្រូវយកចិត្តទុកដាក់ចំពោះភាពចាំបាច់ក្នុងការបន្តដំណើរការនីតិវិធីជំនុំជម្រះ ដោយមិនឲ្យមានការរាំងស្ទះ[19]។

១៥. ប្រហាក់ប្រហែលគ្នានេះដែរ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("តុលាការ ICTY") *អ្នកដែលមិនមែនជាភាគី* មិនត្រូវបានដកចេញដោយផ្អែកលើមូលដ្ឋាននៃការមានផលប្រយោជន៍នៅក្នុងរឿងក្ដីនោះឡើយ។ ពួកគេគ្រាន់តែត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីផលប្រយោជន៍របស់ពួកគេ និង អំពីទំនាក់ទំនង ឬ ការពាក់ព័ន្ធដែលពួកគេមាន ឬ ធ្លាប់មានជា

---

[18] *រដ្ឋអាជ្ញា* តទល់នឹង *Kallon* សំណុំរឿងលេខ SCSL-2003-07-PT សេចក្ដីសម្រេចលើពាក្យសុំរបស់ Redress Trust គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្ស និង គណៈកម្មការអន្តរជាតិសម្រាប់អ្នកច្បាប់ សុំអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី និង សុំបង្ហាញសារណាដោយផ្ទាល់មាត់ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០០៣ កថាខណ្ឌ ៤-៥។

[19] *ដូចខាងលើ* កថាខណ្ឌ ៦។

មួយភាគីណាមួយនៃរឿងក្ដី[20]។ អង្គជំនុំជម្រះតុលាការ ICTY បានអញ្ជើញ ហើយបានទទួលយកសារណារបស់*អ្នកដែលមិនមែនជាភាគី* ពីសមាគមមេធាវីការពារក្ដីដែលបំពេញការងារនៅចំពោះមុខតុលាការ ICTY ("ADC-ICTY")។ ជាឧទាហរណ៍ នៅក្នុងរឿងក្ដី *Brđanin* សមាគមមេធាវីការពារក្ដីដែលបំពេញការងារនៅចំពោះមុខតុលាការ ICTY ត្រូវបានអញ្ជើញឱ្យដាក់សារណារបស់*អ្នកដែលមិនមែនជាភាគី* លើបញ្ហាថាតើសមាជិកនៃសហឧក្រិដ្ឋកម្មរួម ចាំបាច់ត្រូវរួមបញ្ចូលចារីដែលប្រព្រឹត្តបទឧក្រិដ្ឋដោយផ្ទាល់ឬយ៉ាងណា[21]។ នៅក្នុងរឿងក្ដី *Prlić និង អ្នកផ្សេងទៀត* សមាគមមេធាវីការពារក្ដី ដែលបំពេញការងារនៅចំពោះមុខតុលាការ ICTY បានបង្ហាញខ្លួនជា*អ្នកដែលមិនមែនជាភាគី* ពាក់ព័ន្ធបញ្ហាថាតើ ទង្វើរបស់មេធាវីការពារក្ដី អាចជាការប្រមាថតុលាការដែរឬយ៉ាងណា ជាការរំលោភទៅលើវិធានស្ដីពីនីតិវិធី និង ភស្តុតាង ឬ ជាការប្រព្រឹត្តិមិនត្រឹមត្រូវ[22]។

---

[20] *សូមមើល* ព័ត៌មានទាក់ទងនឹងការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ១៩៩៧ IT/122 កថាខណ្ឌ ៣(ក) និង (ច) មាននៅ http://www.icty.org/x/ file/ Legal% 20Library/ Miscellaneous /it 122 _amicuscuriae_briefs_en.pdf។

[21] *សូមមើល រដ្ឋអាជ្ញា* តទល់នឹង *Brđanin* សំណុំរឿងលេខ IT-99-36-A សាលដីកាលើញត្តិស្នើសុំបដិសេធមូលដ្ឋានទីមួយនៃបណ្ដឹងសាទុក្ខរបស់រដ្ឋអាជ្ញា ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៥ ទំព័រ ៥។ សមាគមមេធាវីការពារក្ដី ដែលបំពេញការងារនៅចំពោះមុខតុលាការ ICTY ត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងពេលលើកទឡ្ហីករណ៍ដោយផ្ទាល់មាត់ក្នុងបណ្ដឹងសាទុក្ខ ដោយមាន Michael G. Karnavas ជាប្រធានសមាគមមេធាវីការពារក្ដី ដែលបំពេញការងារនៅចំពោះមុខតុលាការ ICTY បង្ហាញខ្លួនដើម្បីលើកពីសារណារបស់ *អ្នកដែលមិនមែនជាភាគី* នៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៦។ *សូមមើល រដ្ឋអាជ្ញា* តទល់នឹង *Brđanin* សំណុំរឿងលេខ IT-99-36-A សេចក្ដីសម្រេចលើសំណើរបស់សមាគមមេធាវីការពារក្ដី សុំចូលរួមក្នុងការទាញទឡ្ហីករណ៍ផ្ទាល់មាត់ ចុះថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ ២០០៥។ *សូមមើលផងដែរ រដ្ឋអាជ្ញា* តទល់នឹង *Brđanin* សំណុំរឿងលេខ IT-99-36-A សាលដីកាលើបណ្ដឹងសាទុក្ខ ឧបសម្ព័ន្ធ ក៖ សាវតារនីតិវិធី ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០០៧ កថាខណ្ឌ ២៤ ដល់ ២៧។ លោក Karnavas គឺជាសមាជិកបច្ចុប្បន្នរបស់គណៈកម្មាធិការ *amicus* នៃសមាគមមេធាវីការពារក្ដី ដែលបំពេញការងារនៅចំពោះមុខ តុលាការ ICTY ហើយជាសមាជិកនៃគណៈកម្មាធិការវិធាន និង គណៈកម្មាធិការបណ្ដុះបណ្ដាលនៃសមាគមមេធាវីការពារក្ដី ដែលបំពេញការងារនៅចំពោះមុខតុលាការ ICTY ហើយជាអតីតប្រធានសមាគមមេធាវីការពារក្ដី ដែលបំពេញការងារនៅចំពោះមុខតុលាការ ICTY ពីខែ តុលា ឆ្នាំ ២០០៦ ដល់ខែ មីនា ឆ្នាំ ២០០៩។

[22] *សូមមើល រដ្ឋអាជ្ញា* តទល់នឹង *Prlić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-T ដីកាបង្គាប់តែងតាំងអ្នកដែលមិនមែនជាភាគីនៃរឿងក្ដី ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០០៩។ *រដ្ឋអាជ្ញា* តទល់នឹង *Prlić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-

១៦. អ្នកដែលមិនមែនជាភាគី ដែលបានដាក់សារណានៅចំពោះមុខតុលាការកំពូលសហរដ្ឋអាមេរិក ហើយដែលក្នុងពេលបច្ចុប្បន្ន សារណាបែបនេះត្រូវបានដាក់នៅក្នុងរឿងក្ដីជាង ៩០% នោះ[23] ត្រូវបានតម្រូវឱ្យបញ្ជាក់ថា តើសារណានេះគាំទ្រភាគីមួយណា ហើយត្រូវទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីគ្រប់ភាគីទាំងអស់ *ឬ* ត្រូវបង្ហាញពីផលប្រយោជន៍របស់ពួកគេនៅក្នុងរឿងក្ដីនៅពេលដែលដាក់សារណា[24]។ *អ្នកដែលមិនមែនជាភាគី* ដែលបានដាក់សារណា ក៏អាចលើកទឡ្ហីករណ៍ផ្ទាល់មាត់ផងដែរ គាំទ្រភាគីមួយ ដោយមានការឯកភាពពីភាគីនោះ[25]។

---

74-T មតិណែនាំរបស់ក្រុមប្រឹក្សាវិន័យអ្នកដែលមិនមែនជាភាគីនៃរឿងក្ដីនៃសមាគមមេធាវីការពារក្ដីនៅតុលាការ ICTY ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩។

[23] *សូមមើល ដើម្បីជំនួយដល់តុលាការ៖ អន្តរាគមន៍របស់ភាគីទីបីក្នុងចក្រភពអង់គ្លេស យុត្តិធម៌* កថាខណ្ឌ ៥ មាននៅ http://www.justice.org.uk/data/files/resources/32/To-Assist-the-Court-26-October-2009.pdf៖ "រឿងក្ដីទីមួយនៅចំពោះមុខតុលាការកំពូលសហរដ្ឋអាមេរិក ដែលចូលរួមពាក់ព័ន្ធដោយអង្គការមិនមែនរដ្ឋាភិបាល ធ្វើជាអ្នកអន្តរាគមន៍ គឺនៅក្នុងឆ្នាំ ១៩០៤ ហើយក្នុងពេលបច្ចុប្បន្ន សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី ត្រូវបានដាក់ចូលទៅក្នុងរឿងក្ដីជាង ៩០% នៅក្នុងឆ្នាំនីមួយៗ។

[24] *សូមមើល* វិធានរបស់តុលាការកំពូលសហរដ្ឋអាមេរិក វិធាន ៣៧(២) ដែលមាននៅ http://www.supremecourt.gov/ctrules/2013RulesoftheCourt.pdf ។ ជាឧទាហរណ៍មួយនៃសារណារបស់ *អ្នកដែលមិនមែនជាភាគី* ដែលបានដាក់នៅចំពោះមុខតុលាការកំពូលសហរដ្ឋអាមេរិក ដែល *អ្នកដែលមិនមែនជាភាគី* មានផលប្រយោជន៍យ៉ាងប្រាកដក្នុងលទ្ធផលនៃកិច្ចដំណើរការនីតិវិធី *សូមមើល Ridley School Dist.* តទល់នឹង *M.R.* សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដីនៃសមាគមក្រុមប្រឹក្សាភិបាលសាលាថ្នាក់ជាតិ សមាគមក្រុមប្រឹក្សាភិបាលសាលាប្រចាំរដ្ឋ Pennsylvania និង សមាគមជាតិសម្រាប់នាយកនៃការអប់រំពិសេសថ្នាក់រដ្ឋ ដើម្បីគាំទ្រដល់ញត្តិសុំឱ្យមានដីកាបង្គាប់ (Writ of Certiorari)។ សារណារបស់ *អ្នកដែលមិនមែនជាភាគី* ផ្ដើមឡើងដោយមានផ្នែកមួយដែលមានចំណងជើងថា៖ "ផលប្រយោជន៍របស់ *អ្នកដែលមិនមែនជាភាគី*" ដែលថ្លែងថា "*អ្នកដែលមិនមែនជាភាគី* និង បុគ្គលិកសាលាក្នុងស្រុក និង ក្នុងរដ្ឋ ដែលពួកគេតំណាងទូទាំងប្រទេស ជឿជាក់ថា ដំណោះស្រាយទៅលើបញ្ហាចំពោះមុខក្នុងរឿងក្ដីនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ ដែលទាមទារជាចាំបាច់ឱ្យមានការពិនិត្យដោយតុលាការ។ *អ្នកដែលមិនមែនជាភាគី* មានការព្រួយបារម្ភថា ប្រសិនបើទុកចោលមិនដោះស្រាយនោះ ដីកាសម្រេចរបស់សាលាឧទ្ធរណ៍ (Third Circuit) ពាក់ព័ន្ធដែនកំណត់ផ្នែកខាងក្រៅនៃបទប្បញ្ញត្តិរបស់ IDEA ដែលមិនមានការផ្លាស់ប្ដូរ អាចបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់តំបន់សាលារៀន ព្រមទាំងសិស្សដែលសិក្សានៅទីនោះ ដោយជំរុញលើកទឹកចិត្តឱ្យមាតាបិតាសិស្សចូលរួមក្នុងបណ្ដឹងអូសបន្លាយយូរ ជាជាងធ្វើការសហការជាមួយអ្នកអប់រំ ដើម្បីដោះស្រាយជម្លោះដោយគ្មានការពន្យារពេល"។

[25] វិធាន ២៨(៧) របស់តុលាការកំពូលសហរដ្ឋអាមេរិក។

១៧. ដូច្នេះ ផលប្រយោជន៍របស់មេធាវីការពារក្តី ០០៣ ក្នុងការដោះស្រាយទៅលើបញ្ហានៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល មិនមែនជាការរារាំងដល់អង្គជំនុំជម្រះតុលាការកំពូលមិនឱ្យទទួលយកសារណារបស់ *អ្នកដែលមិនមែនជាភាគី* ឡើយ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីការផ្តល់ ឬមិនផ្តល់ការអនុញ្ញាតឱ្យដាក់សារណារបស់ *អ្នកដែលមិនមែនជាភាគី* នេះគួរតែប្រែប្រួលតែក្នុងករណីដែលការទទួលយកសារណានោះមានលក្ខណៈប្រសើរ ឬយ៉ាងណាចំពោះការកាត់សេចក្តីដោយត្រឹមត្រូវទៅលើបញ្ហា។ ចម្លើយគឺវិជ្ជមាន។ សារណា *អ្នកដែលមិនមែនជាភាគី* របស់មេធាវីការពារក្តី ០០៣ នឹងជួយដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការដោះស្រាយបញ្ហាស្មុគស្មាញស្តីពីភាពអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី III នៅ អ.វ.ត.ក. ។ ការអនុញ្ញាតគួរតែត្រូវបានផ្តល់ឱ្យ។

**អាស្រ័យហេតុនេះ** តាមរយៈសំអាងហេតុទាំងអស់ដែលបានបង្ហាញខាងលើ មេធាវីការពារក្តី ០០៣ សូមគោរពស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តាអនុញ្ញាតខ្លួនអាចធ្វើការអន្តរាគមន៍ ដោយផ្ទាល់មាត់ និង ជាលាយលក្ខណ៍អក្សរ នៅក្នុងរឿងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី ០០២/០១។ ក្នុងជម្រើសម្យ៉ាងទៀត មេធាវីការពារក្តី ០០៣ សុំការអនុញ្ញាតដាក់សារណា *អ្នកដែលមិនមែនជាភាគី* ដែលភ្ជាប់មកជាមួយនេះ នៅលើបញ្ហាថា តើសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ត្រូវបានអនុវត្ត ឬ មិនត្រូវបានអនុវត្តនៅឯ អ.វ.ត.ក.។

សូមលោក លោកស្រីចៅក្រម មេត្តាទទួលយកសំណើនេះដោយសេចក្តីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១២** ខែ **មករា** ឆ្នាំ **២០១៥**

សហមេធាវីរបស់ជនសង្ស័យមួយរូបក្នុងរឿងក្តី ០០៣

__________________ __________________

អាង ឧត្តម Michael G. KARNAVAS